# ខ្លឹមសារសង្ខេបប្រតិបត្តិ
# ស្តីពី
# សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣

៚៛៚

សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣ ដែលជាឆ្នាំចុងក្រោយនៃអាណត្តិ នៃរាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភា, ដែលគណៈរដ្ឋមន្ត្រីកំពុងពិនិត្យក្នុងពេលនេះ, ត្រូវបានរៀបចំឡើងនៅក្នុងបរិការណ៍ដែលសេដ្ឋកិច្ចកម្ពុជាក៏កំពុងងើបឡើងវិញ និងត្រឡប់ទៅរកភាពប្រក្រតី បន្ទាប់ពីរាជរដ្ឋាភិបាល, ក្រោមការដឹកនាំប៉ិនប្រសព្វ, វៃឆ្លាត, និងម៉ឺងម៉ាត់ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**, ទទួលបានជោគជ័យដ៏ត្រចះត្រចង់ ក្នុងការប្រយុទ្ធនឹងការរីករាលនៃជំងឺកូវីដ-១៩ និងក្នុងការគ្រប់គ្រងផលប៉ះពាល់ពីវិបត្តិជំងឺនេះបានយ៉ាងល្អ, ទាំងផ្នែកសុខភាពសាធារណៈ, សង្គម-សេដ្ឋកិច្ច, និងផ្នែកជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ, តាមរយៈការដាក់ចេញនូវយន្តការដឹកនាំ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃច្បាស់លាស់, ទាំងកម្រិតគោលនយោបាយ និងយុទ្ធសាស្ត្រ, ពិសេសភាពត្រឹមត្រូវក្នុងការចាត់ទុកវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជា**យុទ្ធសាស្ត្រគន្លឹះ** ដែលធ្វើឱ្យកម្ពុជាទទួលបាននូវវ៉ាក់សាំងទាន់ពេល និងគ្រប់គ្រាន់ ព្រមទាំងដំណើរការចាក់វ៉ាក់សាំងដោយឥតគិតថ្លៃជូនដល់ប្រជាជនប្រកបដោយជោគជ័យតាម "**អភិក្រមផ្ការីក**"។ ជាលទ្ធផល, កម្ពុជាសម្រេចបាននូវ**ភាពស៊ាំក្នុងសហគមន៍**ទូទាំងប្រទេស ដែលអនុញ្ញាតឱ្យកម្ពុជាបើកប្រទេសឡើងវិញចាប់ពីខែវិច្ឆិកា ឆ្នាំ ២០២១ និងបានធ្វើឱ្យសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកចាប់ផ្តើមវិលត្រឡប់ទៅរកប្រក្រតីភាពឡើងវិញ។

ក្នុងន័យនេះ, ថវិកាឆ្នាំ ២០២៣ ត្រូវបានរៀបចំដោយតម្រង់ធនធានឆ្ពោះទៅបន្តរក្សាលំនឹងជីវភាពរស់នៅរបស់ប្រជាជន ក៏ដូចជាលំនឹងនៃសង្គម និងដោយតម្រង់ការវិភាជថវិកាសម្រាប់ការអនុវត្តសកម្មភាពអាទិភាពដែលត្រូវបានកំណត់ក្នុងកម្មវិធី និងអាទិភាពគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល ក្នុងនោះរួមមានជាអាទិ៍៖ ការបន្តគ្រប់គ្រងឱ្យបាននូវការរីករាលដាលនៃជំងឺកូវីដ-១៩ និងការបន្តអន្តរាគមន៍ក្នុងការគ្រប់គ្រងផលប៉ះពាល់ដែលបណ្តាលមកពីជំងឺនេះ; ការបន្តកសាងប្រព័ន្ធគាំពារសង្គមរឹងមាំ និងប្រព័ន្ធសុខាភិបាលប្រកបដោយគុណភាព និងមានភាពឆ្លើយតបខ្ពស់; ការបន្តលើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈ ក៏ដូចជាការកែលម្អប្រព័ន្ធអប់រំឱ្យកាន់តែមានគុណភាពខ្ពស់; ការអនុវត្តកម្មវិធីកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យដែលរាជរដ្ឋាភិបាលបានដាក់ចេញ; និងជាពិសេសការផ្តល់អាទិភាពលើការដំឡើងបៀវត្សជូនមន្ត្រីរាជការគ្រប់ប្រភេទ បន្ទាប់ពីការអាក់ខានពីរឆ្នាំ (២០២១-២០២២) ដើម្បីខិតឱ្យទៅកៀកនឹងគោលនយោបាយបៀវត្សអប្បបរមាដែលរាជរដ្ឋាភិបាលបានកំណត់កាលពីដើមអាណត្តិនៃរាជរដ្ឋាភិបាលនីតិកាលទី ៦ នេះ; ការដំឡើងរបបសោធនជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន; ការបន្តស្តារនិងជំរុញកំណើនសេដ្ឋកិច្ចឱ្យស្ទុះងើបឡើងវិញ ដើម្បីបន្តបង្កើតការងារជូនប្រជាជន ជាពិសេសស្រទាប់យុវជន, និងផ្តល់លទ្ធភាពឱ្យប្រជាជនទទួលបានប្រាក់ចំណូលខ្ពស់ឡើងវិញផង

និងជំរុញបង្កើនចំណូលថវិកាជាតិផង; ការបន្តអភិវឌ្ឍធនធានមនុស្ស; ការបន្តកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តឌីជីថល និងបៃតង; ការបន្តអភិវឌ្ឍ និងការបង្កើនតម្លៃបន្ថែមនៃវិស័យកសិកម្ម; ការជំរុញពិពិធកម្មសេដ្ឋកិច្ច និងភាពប្រកួតប្រជែង; ព្រមទាំងការជានាជោគជ័យនៃកិច្ចដំណើរការ**បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៧** ក៏ដូចជា**ការទ្រទ្រង់និរន្តរភាពនៃប្រតិបត្តិការរបស់រដ្ឋ និងការធ្វើម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ និងអាស៊ានប៉ារ៉ាហ្គេម លើកទី ១២ នៅឆ្នាំ ២០២៣។**

## ១- ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០២៣

ផ្អែកលើការវាយតម្លៃពាក់កណ្តាលឆ្នាំ, សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០២២ ត្រូវបានវាយតម្លៃថានឹងបន្តនិន្នាការកើនឡើងធៀបនឹងកំណើននៅឆ្នាំ ២០២១ ដោយសម្រេចកំណើនក្នុងអត្រាប្រមាណ ៥,៤%, ទោះបីជាទទួលរងផលប៉ះពាល់ពីវិបត្តិសង្គ្រាមរុស្ស៊ី និងអ៊ុយក្រែនយ៉ាងណាក្តី, ដោយសារការបន្តភាពល្អប្រសើរនៃតម្រូវការខាងក្រៅ និងស្របពេលដែលសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកបានវិលត្រឡប់មករកប្រក្រតីភាពវិញបន្ទាប់ពីការប្រកាសបើកប្រទេសឡើងវិញចាប់ពីខែវិច្ឆិកា ឆ្នាំ ២០២១ កន្លងមកនេះ។ ដោយឡែក, សម្រាប់ឆ្នាំ ២០២៣, សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថានឹងសម្រេចបានអត្រាកំណើនក្នុងរង្វង់ ៦,៦% ដែលធ្វើឱ្យ ផសស ថ្លៃបច្ចុប្បន្នស្ថិតក្នុងរង្វង់ **១៣១ ២៧៦ ប៊ីលានរៀល** ឬសមមូលស្មើនឹងប្រមាណ **៣២ ២៩១ លានដុល្លារអាម៉េរិក**, ស្របពេលដែល ផសស សម្រាប់មនុស្សម្នាក់ ត្រូវបានរំពឹងថាកើនឡើងដល់ **១ ៩២៤ ដុល្លារអាម៉េរិក** បើធៀបនឹង **១ ៧៨៥ ដុល្លារអាម៉េរិក** ក្នុងឆ្នាំ ២០២២។

ជារួម, កំណើនសេដ្ឋកិច្ចកម្ពុជាឆ្នាំ ២០២៣ នេះ នឹងត្រូវបានគាំទ្រដោយវិស័យសេដ្ឋកិច្ចសំខាន់ៗ ក្នុងនោះរួមមាន៖

**(ទី១).** វិស័យឧស្សាហកម្មត្រូវបានព្យាករថានឹងបន្តនិន្នាការកើនឡើងក្នុងអត្រា ៩,២% ក្នុងឆ្នាំ ២០២៣ ប្រហាក់ប្រហែលទៅនឹងកំណើនឆ្នាំ ២០២២ ក្នុងអត្រា ៩,០% ដោយសារការរំពឹងទុកលើការបន្តកំណើនរឹងមាំនៃអនុវិស័យកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ ខណៈដែលអនុវិស័យសំណង់ត្រូវបានព្យាករថានៅបន្តងើបឡើងវិញក្នុងអត្រាកំណើនទាបជាងនិន្នាការធម្មតា (មុនវិបត្តិកូវីដ-១៩)។ អនុវិស័យកាត់ដេរ ត្រូវបានរំពឹងថានឹងបន្តកើនឡើងដោយសារការរំពឹងទុកលើភាពល្អប្រសើរនៃតម្រូវការខាងក្រៅ ជាពិសេសទីផ្សារសហរដ្ឋអាម៉េរិក ស្របជាមួយការរំពឹងទុកលើការបង្វែរការបញ្ជាទិញពីប្រទេសក្នុងតំបន់ ដូចជា មីយ៉ាន់ម៉ា ជាដើម។ ការដាក់ចេញនូវ "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ២០២២-២០២៧**" ត្រូវបានរំពឹងថានឹងជួយជំរុញបរិយាកាសវិនិយោគ និងភាពប្រកួតប្រជែងបន្ថែមក្នុងអនុវិស័យនេះផងដែរ។ យ៉ាងណាមិញ, ភាពមិនប្រាកដប្រជាខ្ពស់នៃស្ថានភាពសេដ្ឋកិច្ចសកល ដែលនាំឱ្យមានភាពរង្គោះរង្គើដល់តម្រូវការខាងក្រៅ ជាពិសេសទីផ្សារសំខាន់ៗរបស់កម្ពុជា រួមមាន សហរដ្ឋអាម៉េរិក និងសហភាពអឺរ៉ុប អាចនឹងបង្កជាបច្ច័យអវិជ្ជមានដល់អនុវិស័យនេះផងដែរ។ អនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ រំពឹងថានៅបន្តសម្រេចបានកំណើនល្អប្រសើរ ដែលមួយផ្នែកនឹងបន្តជំរុញដោយការរក្សាបានតុល្យភាពនៃផលិតកម្មដែលបម្រើឱ្យតម្រូវការក្នុងស្រុក និងមួយផ្នែកទៀតគាំទ្រដោយការរំពឹងទុកកំណើនល្អប្រសើរនៃផលិតកម្មបម្រើឱ្យការនាំចេញ។ និន្នាការល្អប្រសើរនៃតម្រូវការខាងក្រៅ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី នឹងបន្តជំរុញកំណើននៃអនុវិស័យនេះលើផ្នែកផលិតកម្មបម្រើការនាំចេញ ជាពិសេសទៅលើផលិតផលសំខាន់ៗ មួយចំនួនរួមមាន៖ គ្រឿងសង្ហារិម, ស្បែកសត្វមានរោម, ក្តារកុងប្លាកេ, ឈើមូល ឬឈើអារ និងឈើ veneer, វត្ថុសម្រាប់ដាងសំណង់ធ្វើពីប្លាស្ទិក, បន្ទះសូឡា, គ្រឿងអេឡិចត្រូនិក និងភាគបំណែក, ខ្សែភ្លើង និងបង្គុំខ្សែភ្លើង, ស្ករស, និងកសិផលកែច្នៃផ្សេងៗ ជាដើម។ ទន្ទឹមនេះ, ការដាក់ចេញនូវ "**ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា**" នឹងអាចរួមចំណែកបង្កើនបរិយាកាសវិនិយោគឱ្យកាន់តែមានភាពទាក់ទាញ និងប្រសើរជាងមុន។ ដោយឡែកអនុវិស័យសំណង់ត្រូវបាន

រំពឹងថានឹងបន្តកំណើនទាបជាងនិន្នាការធម្មតាដោយសារការរំពឹងទុកការងើបឡើងវិញយឺតនៃលំហូរទុនវិនិយោគពីបរទេស ជាពិសេសសម្រាប់សំណង់ថ្លៃខ្ពស់ ក៏ដូចជាសំណង់បម្រើឱ្យវិស័យទេសចរណ៍ និងពាណិជ្ជកម្ម ស្របពេលដែលសកម្មភាពសំណង់លំនៅឋានក៏ត្រូវបានរំពឹងថានៅបន្តរក្សាកំណើន ប៉ុន្តែស្ថិតក្នុងកម្រិតទាប។

**(ទី២).** វិស័យសេវាកម្មត្រូវបានព្យាករថានឹងបន្តកើនឡើងក្នុងអត្រា ៦,៦% ក្នុងឆ្នាំ ២០២៣ ពីកំណើន ៤,៣% ក្នុងឆ្នាំ ២០២២ ដោយសារការបន្តងើបឡើងនូវសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក ជាពិសេសអនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន និងវិស័យគាំទ្រទេសចរណ៍ផ្សេងៗទៀត។ អនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋានត្រូវបានរំពឹងថាបន្តនិន្នាការងើបឡើងវិញ ដោយសារការរំពឹងទុកលើការងើបឡើងវិញនៃភ្ញៀវទេសចរអន្តរជាតិ ស្របពេលដែលភ្ញៀវទេសចរជាតិក៏ត្រូវបានរំពឹងថានឹងបន្តកើនឡើង ជាមួយនឹងសន្ទុះលឿនជាងភ្ញៀវទេសចរអន្តរជាតិ ដោយសារការដកចេញនូវរបាំងធ្វើដំណើរផ្សេងៗ និងការវិលត្រឡប់រកប្រក្រតីភាពវិញនៃសង្គម-សេដ្ឋកិច្ច។ អនុវិស័យលក់ដុំ-រាយ ត្រូវបានរំពឹងថានឹងបន្តនិន្នាការកើនឡើង ដោយសារការរំពឹងទុកលើការបន្តងើបឡើងវិញនូវចំណូលរបស់ប្រជាជន និងសកម្មភាពចាយវាយក្នុងស្រុក គួបផ្សំនឹងការផ្លាស់ប្តូរឥរិយាបថនៃអាជីវកម្ម ក៏ដូចជាសកម្មភាពទិញ-លក់ពីបែបប្រពៃណី (Brick-And-Morta) ដោយជំនួសមកវិញនូវការប្រើប្រាស់ថ្នាលឌីជីថល ដែលការណ៍នេះនឹងបន្តជំរុញបន្ថែមទៀតដល់សកម្មភាពប្រើប្រាស់ក្នុងស្រុកជារួម។ អនុវិស័យអចលនទ្រព្យ ត្រូវបានរំពឹងថានឹងបន្តនិន្នាការកើនឡើង ប៉ុន្តែក្នុងល្បឿនយឺត ដោយសារការរំពឹងទុកលើការបន្តងើបឡើងវិញយឺតនៃលំហូរទុនវិនិយោគពីបរទេស និងកំណើនទាបនៃសកម្មភាពទិញ-លក់អចលនទ្រព្យជារួម ។ អនុវិស័យដឹកជញ្ជូន និងគមនាគមន៍ ត្រូវបានរំពឹងថានឹងបន្តកើនឡើង គាំទ្រដោយការបន្តងើបឡើងនៃសកម្មភាពដឹកជញ្ជូនបម្រើឱ្យវិស័យទេសចរណ៍ និងពាណិជ្ជកម្ម ស្របពេលដែលសកម្មភាពគមនាគមន៍ក៏នៅបន្តរក្សានិន្នាការល្អប្រសើរ ដោយសារការបន្តកើនឡើងនូវការប្រើប្រាស់អ៊ីនធឺណិត និងឌីជីថលក្នុងអាជីវកម្ម និងជីវភាពប្រចាំថ្ងៃក្នុងគន្លងប្រក្រតីភាពថ្មី ។ ទន្ទឹមនេះ, ការដាក់ចេញ និងអនុវត្តនូវ "**ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥**" នឹងបង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល ព្រមទាំងនឹងលើកកម្ពស់ការប្រើប្រាស់ទំនិញ និងសេវាឌីជីថលនៅកម្ពុជា។

**(ទី៣).** វិស័យកសិកម្មត្រូវបានរំពឹងថានៅបន្តនិន្នាការកើនឡើង ក្នុងអត្រា ១,១% ក្នុងឆ្នាំ ២០២៣ ធៀបនឹង ០,៧% ក្នុងឆ្នាំ ២០២២ ដោយសារការរំពឹងទុកលើការបន្តរក្សាកំណើនល្អប្រសើរនៃអនុវិស័យដំណាំ និងចិញ្ចឹមសត្វ ស្របពេលដែលអនុវិស័យនេសាទ ត្រូវបានរំពឹងថានឹងងើបឡើងវិញ ។ អនុវិស័យដំណាំត្រូវបានរំពឹងថានឹងបន្តកើនឡើង ដោយសារការរំពឹងទុកកំណើនល្អប្រសើរនៃការនាំចេញផលិតផលកសិកម្ម ជាពិសេសដំណាំរួមផ្សំ និងឧស្សាហកម្មដែលនឹងបន្តជំរុញដោយកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី គួបផ្សំជាមួយនឹងការបង្កើនការវិនិយោគរបស់រាជរដ្ឋាភិបាល ជាពិសេស ការផ្តល់ហិរញ្ញប្បទានក្នុងការជំរុញផលិតកម្មក្នុងស្រុក ។ អនុវិស័យចិញ្ចឹមសត្វត្រូវបានរំពឹងថានឹងនៅបន្តរក្សាកំណើនខ្ពស់ ដោយសារការរំពឹងទុកលើការបន្តកើនឡើងនៃផលិតកម្មជ្រូក គួបផ្សំនឹងវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាល និងការអនុវត្តគម្រោងរបស់ដៃគូអភិវឌ្ឍនានា ។ ទន្ទឹមនេះ, អនុវិស័យនេសាទ ត្រូវបានរំពឹងថានឹងងើបឡើងវិញផ្អែកលើការរំពឹងទុកនូវការកើនឡើងសន្សឹមៗ ទាំងផលចាប់ទឹកសាប និងផលិតកម្មវារីវប្បកម្ម, ដោយសារការអនុវត្តវិធានការរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍតាមរយៈការដោះស្រាយបញ្ហាប្រឈមជារចនាសម្ព័ន្ធ, ការគាំទ្រផ្នែកហិរញ្ញប្បទាន, ការផ្សព្វផ្សាយបច្ចេកទេស និងការប្រើប្រាស់ពូជត្រីប្រកបដោយប្រសិទ្ធភាពខ្ពស់ និងគុណភាព។

**អតិផរណាមធ្យមប្រចាំឆ្នាំ** ត្រូវបានរំពឹងថាកើនឡើងក្នុងរង្វង់ ២,៥% ក្នុងឆ្នាំ ២០២៣ ដោយសារការរំពឹងទុកលើការវិលត្រលប់ទៅរកនិន្នាការធម្មតាវិញនៃថ្លៃប្រេងអន្តរជាតិ។ ទោះជាយ៉ាងនេះក្តី, ស្ថានភាពអតិផរណាដែលបានគ្រោងនេះ អាចនឹងបន្តកើនឡើងខ្ពស់ជាងការរំពឹងទុក ដោយសារការបន្តអូសបន្លាយនៃថ្លៃ

ទំនិញអន្តរជាតិ, ជាពិសេសថ្លៃប្រេងឥន្ធនៈ, ដែលបង្កឡើងដោយកត្តាផ្គត់ផ្គង់ (Supply shock)។ ចំណែកឯ **អត្រាប្តូរប្រាក់រៀល** ត្រូវបានប៉ាន់ស្មានថានឹងនៅតែបន្តមានស្ថិរភាពក្នុងរង្វង់ **៤ ០៦៥ រៀល** ក្នុងមួយដុល្លារអាម៉េរិកក្នុងឆ្នាំ ២០២៣ ដោយសារការបន្តអនុវត្តវិធានការលើកកម្ពស់ប្រាក់រៀលរបស់ធនាគារជាតិនៃកម្ពុជា និងការបន្តពង្រឹងគោលនយោបាយគ្រប់គ្រងសាច់ប្រាក់ក្នុងវិស័យហិរញ្ញវត្ថុ។ **ឱនភាពគណនីចរន្ត (រួមបញ្ចូលបង្វែរ)** ត្រូវបានរំពឹងថានឹងបន្តរួមតូចមកត្រឹម ១៤,១% នៃ ផសស សម្រាប់ឆ្នាំ ២០២៣ ដោយសារការរំពឹងទុកលើការបន្តកើនឡើងនូវការនាំចេញ និងចំណូលពីវិស័យទេសចរណ៍។ **ទុនបម្រុងអន្តរជាតិសរុប** ត្រូវបានរំពឹងថានឹងបន្តកើនឡើងដល់ **២២ ១៤៩ លានដុល្លារអាម៉េរិក** ក្នុងឆ្នាំ ២០២៣ និងធានាការនាំចូលបាន ៧,៦ ខែ។

ជារួម បើទោះបីជាសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០២៣ ត្រូវបានរំពឹងថានឹងងើបឡើងវិញក្នុងអត្រាដូចខាងលើក៏ដោយ, សេដ្ឋកិច្ចកម្ពុជាក៏ត្រូវជួបបញ្ហាប្រឈម និងហានិភ័យមួយចំនួន ទាំងក្នុង និងក្រៅប្រទេស ដូចខាងលើដែលអាចនឹងធ្វើឱ្យប៉ះពាល់ដល់កំណើនសេដ្ឋកិច្ច និងបង្កភាពអាក់អួលដល់កិច្ចអភិវឌ្ឍន៍ជារួម។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តជំរុញអនុវត្ត "**ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣**" ក្នុងគោលបំណងស្តារ និងពង្រឹងសក្តានុពលនៃចន្ទល់កំណើនសេដ្ឋកិច្ចឱ្យរស់រវើក និងត្រឡប់ទៅកំណើនសក្តានុពល ប្រកបដោយចីរភាព និងបរិយាបន្ន, ចាប់យកឱ្យបាននូវកាលានុវត្តភាពថ្មីៗដែលកំពុងលេចឡើង ស្របនឹងនិន្នាការតំបន់ និងសកល និងកសាងភាពធន់នៃសង្គម-សេដ្ឋកិច្ច។

## ២-ក្របខ័ណ្ឌគោលនយោបាយថវិកាឆ្នាំ ២០២៣

ថវិកាឆ្នាំ ២០២៣, ដែលត្រូវបានរៀបចំដោយឈរលើមូលដ្ឋាននៃក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដូចបានគូសបញ្ជាក់ខាងលើ និងក្នុងគោលដៅបន្តបម្រើឱ្យបណ្តាអាទិភាពនៃ "**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤**", **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣** និងជាពិសេស **ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣**, មានគោលបំណងសំខាន់ៗ ដូចខាងក្រោម៖

- បន្តពង្រឹងសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ;
- បន្តធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ច ក្នុងរយៈពេលមធ្យម ប្រកបដោយបរិយាប័ន្ន;
- បន្តស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឱ្យត្រឡប់ទៅរកកំណើនជាសក្តានុពល តាមរយៈការជំរុញការអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣;
- ជំរុញការអភិវឌ្ឍប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គម ដើម្បីលើកកម្ពស់សុខុមាលភាពសង្គម និង កសាងភាពធន់នៃសង្គមកម្ពុជា សម្រាប់ត្រៀមឆ្លើយតបទៅនឹងគ្រោះអាសន្ន ដែលអាចកើតមានជាយថាហេតុ;
- ជំរុញការអភិវឌ្ឍធនធានមនុស្ស ដោយការលើកកម្ពស់គុណភាពអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសគ្រប់កម្រិត ដើម្បីផ្គត់ផ្គង់ពលករជំនាញ ប្រកបដោយផលិតភាពខ្ពស់ ឱ្យបានគ្រប់គ្រាន់ និងឆ្លើយតបនឹងតម្រូវការទីផ្សារ;
- ដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ព្រមទាំងប្រាក់ឧបត្ថម្ភមន្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមក្នុងកម្រិតសមស្រប ដោយផ្អែកលើសមិទ្ធកម្ម ឬគុណាធិបតេយ្យ ដើម្បីលើក-កម្ពស់ជីវភាពរស់នៅ ព្រមទាំងពង្រឹងសមត្ថភាពស្ថាប័ន និងគុណភាពនៃការផ្តល់សេវាសាធារណៈ;

- ដំឡើងប្រាក់សោធន និងកាត់បន្ថយគម្លាតនៃប្រាក់សោធនរវាងអ្នកចូលនិវត្តន៍ចាស់ និងថ្មី ជូនដល់អតីតមន្ត្រីរាជការស៊ីវិល និងអតីតកងកម្លាំងប្រដាប់អាវុធ;
- បន្តជំរុញការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, កម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងកម្មវិធីកែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ;
- ជំរុញការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងការអភិវឌ្ឍបៃតង សំដៅលើកកម្ពស់ការតភ្ជាប់ក្នុងសេដ្ឋកិច្ច, គាំទ្រការធ្វើបរិវត្តកម្មឌីជីថល និងអភិវឌ្ឍប្រកបដោយចីរភាព;
- បន្តគាំទ្រការអភិវឌ្ឍនៃសហគ្រាសធុនតូច និងមធ្យម តាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, ការដាក់ចេញវិធានការលើកទឹកចិត្តជាក់លាក់ និងការកែលម្អបរិយាកាសធុរកិច្ច; និង
- ធានាជោគជ័យនៃកិច្ចដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៧ និងការធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ និងអាស៊ានប៉ារ៉ាហ្គេម ឆ្នាំ ២០២៣ ព្រមទាំង ការត្រៀមសម្រាប់ការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភានីតិកាលទី ៥។

ដើម្បីសម្រេចបាននូវគោលបំណងសំខាន់ៗខាងលើ ថវិកាឆ្នាំ ២០២៣ ត្រូវបានរៀបចំឡើងដោយប្រកាន់យកគោលការណ៍គ្រឹះជាយុទ្ធសាស្ត្រសំខាន់ៗ ចំនួន ៥ និងគោលការណ៍បច្ចេកទេសសំខាន់ៗ ចំនួន ៦ ដូចខាងក្រោម៖

## ក. គោលការណ៍គ្រឹះជាយុទ្ធសាស្ត្រសំខាន់ៗ ៖

**គោលការណ៍ទី ១)**-ការតម្កល់ "**មនុស្ស**" ជាអាទិភាពទី ១ ដោយផ្តោតលើ៖ (១)-ការបន្ត និងការពង្រីកនូវការអនុវត្តគោលនយោបាយគាំពារសង្គម សំដៅជួយគាំពារជនក្រីក្រ និងក្រុមជនងាយរងគ្រោះ ដែលទទួលរងផលប៉ះពាល់ពីវិបត្តិនៃជំងឺកូវីដ-១៩ និងពីការឡើងថ្លៃទំនិញដោយសារវិបត្តិនៃសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន; (២)-ការបន្តចំណាយលើការពង្រឹងប្រព័ន្ធសុខាភិបាល និងគុណភាពវិស័យអប់រំ (៣)-ការដំឡើងបៀវត្សជូនមន្ត្រីរាជការ ឱ្យខិតទៅកៀកនឹងគោលដៅនៃគោលនយោបាយបៀវត្សអប្បបរមា ដែលត្រូវបានកំណត់កាលពីដើមអាណត្តិនៃរាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភា ក្នុងគោលដៅលើកកម្ពស់ជីវភាពរស់នៅ និងបង្កើនផលិតភាពការងារ; (៤)-ការដំឡើងប្រាក់សោធនជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈជាអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ជាពិសេសការកាត់បន្ថយគម្លាតប្រាក់សោធនរវាងអ្នកចូលនិវត្តន៍ចាស់ និងថ្មី; និង (៥)-ការពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ដោយឈរលើគោលការណ៍សមធម៌, គុណាធិបតេយ្យ និងចីរភាពថវិកា, ព្រមទាំងការបន្តបង្កើតការងារជូនប្រជាជន, ពិសេសស្រទាប់យុវជន, ដែលផ្តល់លទ្ធភាពឱ្យទទួលបានប្រាក់ចំណូលសមស្រប ។

**គោលការណ៍ទី ២)**-ការធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ជាពិសេសការគ្រប់គ្រងបាននូវអតិផរណា និងការធានាស្ថិរភាពនៃអត្រាប្តូរប្រាក់ ព្រមទាំងស្ថិរភាពហិរញ្ញវត្ថុជាទូទៅ ។

**គោលការណ៍ទី ៣)**-ការបន្តស្តារ និងទ្រទ្រង់ការរីកចម្រើនមូលដ្ឋានសង្គម-សេដ្ឋកិច្ចជាតិ ស្របតាមការចង្អុលបង្ហាញក្នុងក្របខ័ណ្ឌ "**យុទ្ធសាស្ត្រ និងកម្មវិធីស្តារនិងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣**" ។

**គោលការណ៍ទី ៤)**-ការបន្តនិរន្តរភាពនៃប្រតិបត្តិការរបស់រដ្ឋ និងការបន្តជំរុញអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល ដើម្បីពង្រឹងភាពប្រកួតប្រជែង និងពិពិធកម្មសេដ្ឋកិច្ច សំដៅធានាស្ថិរភាពកំណើន គាំទ្រដល់ការស្តារសេដ្ឋកិច្ច និងឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រជា-

ផនតាមការសន្យា ក៏ដូចជាពង្រឹងគ្រឹះក្នុងការកសាងស្ថាប័ន និងសមត្ថភាពនៃវិស័យសាធារណៈ ក្នុងគោលដៅពង្រីកវិសាលភាព និងពង្រឹងគុណភាពនៃសេវាសាធារណៈ និងសេវាយុត្តិធម៌; ព្រមទាំងការបន្តអនុវត្តឱ្យបានជាអតិបរមានូវកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនៅឆ្នាំ ២០២៣ ដែលជាឆ្នាំចុងអាណត្តិនៃរាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា ។

គោលការណ៍ទី ៥ )-ការគិតគូរអំពីគ្រប់ទិដ្ឋភាពនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៧ ។

**ខ. គោលការណ៍បច្ចេកទេសសំខាន់ៗ ៖**

(ទី១)-ការធានានាថីរភាព និងសមិទ្ធកម្មនៃចំណូល,

(ទី២)-ការធ្វើវិចារណកម្មលំដាប់អាទិភាព,

(ទី៣)-ការកែលម្អការរៀបចំកម្មវិធី/សកម្មភាព,

(ទី៤)-ការផ្ទេរថវិកាឱ្យដល់អង្គភាពអនុវត្ត,

(ទី៥)-ការផ្សារភ្ជាប់រវាងការប្រមូលចំណូល និងការរិកាជថវិកា,

(ទី៦)-ការរក្សាតុល្យភាព និងចីរភាពថវិកា ។

## ៣-ក្របខ័ណ្ឌថវិកាឆ្នាំ ២០២៣

ឈរលើគោលការណ៍ និង ក្នុងគោលបំណងសម្រេចឱ្យបាននូវគោលនយោបាយខាងលើ, ក្របខ័ណ្ឌថវិកាឆ្នាំ ២០២៣ ត្រូវបានកំណត់ដូចខាងក្រោម៖

| សូចនាករថវិកា | ២០២១ | | ២០២២ | ២០២៣ |
|---|---|---|---|---|
| | ច្បាប់ | អនុវត្ត | ច្បាប់ | គ្រោង |
| **ចំណូលក្នុងប្រទេសថវិការដ្ឋ ឬ ថវិកាជាតិ (% ផសស)** | **19.41** | **20.66** | **21.27** | **22.33** |
| - ចំណូលចរន្ត (% ផសស) | 19.21 | 20.60 | 20.19 | 21.46 |
| **ចំណាយសរុបថវិការដ្ឋ ឬ ថវិកាជាតិ (% ផសស)** | **28.97** | **30.93** | **28.85** | **29.87** |
| - ចំណាយចរន្ត (% ផសស) | 16.97 | 19.27 | 17.33 | 17.47 |
| **អតិរេកចរន្ត (% ផសស)** | **2.24** | **1.33** | **2.86** | **3.99** |
| **ឱនភាពសរុប (% ផសស)** | **-9.56** | **-10.27** | **-7.58** | **-7.54** |

**ចំណូលក្នុងប្រទេសថវិការដ្ឋ ឬ ថវិកាជាតិ** ត្រូវបានគ្រោងចំនួន ២៩ ៣១១ ៧៤៧ លានរៀល ស្មើនឹង ២២,៣៣% នៃ ផសស, មានកំណើន ១៤,៥% ធៀបនឹងច្បាប់ឆ្នាំ ២០២២។ ចំណែកឯ **ចំណាយសរុបថវិការដ្ឋ ឬ ថវិកាជាតិ** ត្រូវបានគ្រោងចំនួន ៣៩ ២០៦ ២០៥ លានរៀល ស្មើនឹង ២៩,៨៧% នៃ ផសស, មានកំណើន ១៣,០% ធៀបនឹងច្បាប់ឆ្នាំ ២០២២។ ជាលទ្ធផល **អតិរេកថវិកាចរន្ត** អាចរក្សាបានក្នុងកម្រិតប្រមាណ **៣,៩៩%** នៃ ផសស នៅឆ្នាំ ២០២៣ និងមាន **ឱនភាពថវិកាសរុប** ស្មើនឹង **-៧,៥៤%** នៃ ផសស។ ឱនភាពនេះ ត្រូវបានបំពេញតុល្យភាពដោយ៖ (១)- **ហិរញ្ញប្បទានក្រៅប្រទេស** ក្នុងទំហំ **៤,៧០%** នៃ ផសស, (២)- **មូលនិធិទ្រទ្រង់ថវិកា** ក្នុងទំហំ **០,៩៨%** នៃ ផសស, (៣)- **ប្រាក់បញ្ញើរាជរដ្ឋាភិបាល** ក្នុងទំហំ **១,៨៦%** នៃ ផសស ស្មើនឹង **២ ៤៣៩ ប៊ីលានរៀល ឬ សមមូលនឹង ៦០០ លានដុល្លារអាម៉េរិក និងការបោះផ្សាយមូលបត្ររដ្ឋ ចំនួន ៨១៣ ប៊ីលានរៀល ឬសមមូលនឹងប្រមាណ ២០០ លានដុល្លារអាម៉េរិក** ដើម្បីបំពេញតម្រូវការចំណាយ ទាំង

ចំណាយចរន្ត និងចំណាយវិនិយោគសាធារណៈ ជាពិសេសសម្រាប់ការបន្តអនុវត្តកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញក្នុងបរិការណ៍នៃការរស់នៅជាមួយនឹងជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី និង**ការត្រៀមដោះស្រាយថវិកាសម្រាប់អគ្គិសនីកម្ពុជា ដើម្បីធានាស្ថេរភាពថ្លៃអគ្គិសនីកុំឱ្យកើនលើសកម្រិតថ្លៃកំពុងអនុវត្តបច្ចុប្បន្ន ជូនប្រជាពលរដ្ឋប្រើប្រាស់** ។

## ៤-គម្រោងចំណូល-ចំណាយថវិការដ្ឋ

### ៤.១-គម្រោងចំណូលថវិការដ្ឋ

| ចំណូលថវិកា (ឯកតាលានរៀល) | ២០២២ | | ២០២៣ | | % កំណើន |
|---|---|---|---|---|---|
| | ច្បាប់ | % ផសស | គ្រោង | % ផសស | |
| **សរុបចំណូលថវិការដ្ឋ ឬ ថវិកាជាតិ** | **32,676,130** | **27.16%** | **36,767,670** | **28.01%** | **12.5%** |
| *• ថ្នាក់ជាតិ* | 30,544,366 | 25.39% | 34,165,163 | 26.03% | 11.9% |
| *• ថ្នាក់ក្រោមជាតិ* | 2,131,764 | 1.77% | 2,602,507 | 1.98% | 22.1% |
| **១. ចំណូលចរន្តថវិការដ្ឋ** | **24,289,107** | **20.19%** | **28,166,935** | **21.46%** | **16.0%** |
| ***ក. ចំណូលសារពើពន្ធថវិការដ្ឋ*** | **21,811,132** | **18.13%** | **25,594,274** | **19.50%** | **17.3%** |
| *- ថ្នាក់ជាតិ* | 20,227,005 | 16.81% | 23,421,924 | 17.84% | 15.8% |
| *- ថ្នាក់ក្រោមជាតិ* | 1,584,127 | 1.32% | 2,172,350 | 1.65% | 37.1% |
| ***ខ. ចំណូលមិនមែនសារពើពន្ធថវិការដ្ឋ*** | **2,477,975** | **2.06%** | **2,572,661** | **1.96%** | **3.8%** |
| *- ថ្នាក់ជាតិ* | 1,930,338 | 1.60% | 2,142,504 | 1.63% | 11.0% |
| *- ថ្នាក់ក្រោមជាតិ* | 547,637 | 0.46% | 430,157 | 0.33% | -21.5% |
| **២. ចំណូលមូលធនថវិការដ្ឋ** | **8,387,023** | **6.97%** | **8,600,735** | **6.55%** | **2.5%** |
| *• ក្នុងប្រទេស* | 1,305,259 | 1.08% | 1,144,812 | 0.87% | -12.3% |
| *• ក្រៅប្រទេស* | 7,081,764 | 5.89% | 7,455,923 | 5.68% | 5.3% |

ក្នុងក្របខ័ណ្ឌនៃគោលដៅខាងលើ រាជរដ្ឋាភិបាលត្រូវ**បង្កើនចំណូលសរុបថវិការដ្ឋ ឬ ចំណូលសរុបថវិកាជាតិ**ឱ្យស្មើនឹង ៣៦ ៧៦៧ ៦៧០ លានរៀល ក្នុងនោះ ចំណូលចរន្តថ្នាក់ជាតិឱ្យស្មើនឹង ២៥ ៥៦៤ ៤២៨ លានរៀល (ដែលរួមមាន ចំណូលសារពើពន្ធ ២៣ ៤២១ ៩២៤ លានរៀល និង ចំណូលមិនមែនសារពើពន្ធ ២ ១៤២ ៥០៤ លានរៀល)។ ដោយឡែក ចំណូលមូលធនថវិការដ្ឋ ត្រូវបានគ្រោងចំនួន ៨ ៦០០ ៧៣៥ លានរៀល, ត្រូវជា ៦,៥៥% នៃ ផសស, មានកំណើន ២,៥% ធៀបនឹងច្បាប់ឆ្នាំ ២០២២ ក្នុងនោះចំណូលមូលធនក្រៅប្រទេសស្មើនឹងប្រមាណ ១៩% នៃចំណាយថវិការដ្ឋសរុបឆ្នាំ ២០២៣ ប៉ុណ្ណោះ។

### ៤.២-គម្រោងចំណាយថវិការដ្ឋ

សម្រាប់ឆ្នាំ ២០២៣ **ចំណាយសរុបថវិការដ្ឋ ឬ ចំណាយសរុបថវិកាជាតិ** ត្រូវបានគ្រោងចំនួន **៣៩ ២០៦ ២០៥ លានរៀល** ត្រូវជា ២៩,៨៧% នៃ ផសស, មានកំណើន ១៣,០% ធៀបនឹងច្បាប់ឆ្នាំ ២០២២ ដែលក្នុងនោះ៖ (១)-**ចំណាយចរន្តថវិការដ្ឋមានចំនួន ២២ ៩២៨ ៩៣២ លានរៀល**, ត្រូវជា ១៧,៤៧% នៃ ផសស, កើនឡើង ១០,០% ធៀបនឹងច្បាប់ឆ្នាំ ២០២២; និង (២)-**ចំណាយមូលធនថវិការដ្ឋមានចំនួន ១៦ ២៧៧ ២៧៣ លានរៀល**, ត្រូវជា ១២,៤០% នៃ ផសស, មានកំណើន ១៧,៥% ធៀបនឹងច្បាប់ឆ្នាំ ២០២២។

| ចំណាយថវិកា<br>(ឯកតាលានរៀល) | ២០២២ | | ២០២៣ | | % កំណើន |
|---|---|---|---|---|---|
| | ច្បាប់ | % ផសស | គ្រោង | % ផសស | |
| **សរុបចំណាយថវិការដ្ឋ ឬ ថវិកាជាតិ** | **34,708,630** | **28.85%** | **39,206,205** | **29.87%** | **13.0%** |
| *• ថ្នាក់ជាតិ* | 32,576,866 | 27.08% | 36,603,698 | 27.88% | 12.4% |
| *• ថ្នាក់ក្រោមជាតិ* | 3,394,814 | 2.82% | 4,061,797 | 3.09% | 19.6% |
| **១. ចំណាយចរន្តថវិការដ្ឋ** | **20,850,440** | **17.33%** | **22,928,932** | **17.47%** | **10.0%** |
| ***១.១. ថ្នាក់ជាតិ*** | **19,111,704** | **15.89%** | **20,839,425** | **15.87%** | **9.0%** |
| *•បន្ទុកបុគ្គលិក* | 8,653,955 | 7.19% | 9,555,197 | 7.28% | 10.4% |
| *•ក្រៅបន្ទុកបុគ្គលិក* | 10,457,749 | 8.69% | 11,284,229 | 8.60% | 7.9% |
| ***១.២. ថ្នាក់ក្រោមជាតិ*** | **3,001,786** | **2.49%** | **3,548,797** | **2.70%** | **18.2%** |
| *•បន្ទុកបុគ្គលិក* | 779,801 | 0.65% | 879,914 | 0.67% | 12.8% |
| *•ក្រៅបន្ទុកបុគ្គលិក* | 2,221,985 | 1.85% | 2,668,883 | 2.03% | 20.1% |
| **២. ចំណាយមូលធនថវិការដ្ឋ** | **13,858,190** | **11.52%** | **16,277,273** | **12.40%** | **17.5%** |
| *- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស* | 6,567,049 | 5.46% | 8,243,971 | 6.28% | 25.5% |
| *+ ក្នុងនោះចំណាយមូលធនថ្នាក់ក្រោមជាតិ* | 393,028 | 0.33% | 513,000 | 0.39% | 30.5% |
| *- ការទូទាត់ប្រាក់ខ្ចី* | 1,477,657 | 1.23% | 1,859,887 | 1.42% | 25.9% |
| *- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស* | 5,813,484 | 4.83% | 6,173,415 | 4.70% | 6.2% |

### ៤.២.១-ថវិកាថ្នាក់ជាតិ

ថវិកាឆ្នាំ ២០២៣ មានទិសដៅជាយុទ្ធសាស្ត្រកំណត់**ចំណាយថវិកាថ្នាក់ជាតិ**ឱ្យស្ថិតក្នុងកម្រិតចំនួន ៣៦ ៦០៣ ៦៩៨ លានរៀល ត្រូវជា ២៧,៨៨% នៃ ផសស, មានកំណើន ១២,៤% ធៀបនឹងច្បាប់ឆ្នាំ ២០២២ ដែលក្នុងនោះ **ចំណាយចរន្តថ្នាក់ជាតិ** មានចំនួន ២០ ៨៣៩ ៤២៥ លានរៀល និង **ចំណាយមូលធនថ្នាក់ជាតិ**មានចំនួន ១៥ ៧៦៤ ២៧៣ លានរៀល។

**ក. ចំណាយបន្ទុកបុគ្គលិក** ត្រូវបានគ្រោងចំនួន ៩ ៥៥៥ ១៩៧ លានរៀល សម្រាប់៖ (១)-ការជ្រើសរើសក្របខ័ណ្ឌថ្មី ជំនួសអ្នកចូលនិវត្តន៍ក្នុងឆ្នាំ ២០២២ និង ការជ្រើសរើសក្របខ័ណ្ឌគ្រូបង្រៀនឡើងវិញចំនួន ៣ ០០០ កន្លែង បន្ទាប់ពីអាក់ខានចំនួន ២ ឆ្នាំ កន្លងមក; (២)-ការដំឡើងបៀវត្សជូនមន្ត្រីរាជការឡើងវិញ បន្ទាប់ពីបានផ្អាកការដំឡើងនៅឆ្នាំ ២០២១ និង ឆ្នាំ ២០២២ ដោយសារវិបត្តិជំងឺកូវីដ-១៩ ដែលតម្រូវឱ្យរាជរដ្ឋាភិបាលធ្វើវិចារណកម្មចំណាយដើម្បីបង្វែរធនធានទៅដោះស្រាយផលប៉ះពាល់ពីវិបត្តិនៃជំងឺនេះ; និង (៣)-ការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់**មន្ត្រីជាប់កិច្ចសន្យា** ពី ៦៧ ម៉ឺនរៀល ទៅដល់ **៧១ ម៉ឺនរៀល** ដោយអនុវត្តចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ ២០២៣។

ជារួម នៅឆ្នាំ ២០២៣ បៀវត្សអប្បបរមារបស់មន្ត្រីរាជការស៊ីវិល និង កងកម្លាំងប្រដាប់អាវុធ នឹងមានស្ថានភាពកើនឡើងដូចខាងក្រោម៖

- **បៀវត្សមន្ត្រីរាជការស៊ីវិល** នឹងត្រូវបានដំឡើងពីចំនួន ១ ១៧២ ៥០០ រៀល នៅឆ្នាំ ២០២២ ដល់ប្រមាណ **១ ៣០០ ០០០** រៀល ចាប់ពីខែមករា ឆ្នាំ ២០២៣;
- **បៀវត្សគ្រូបង្រៀន និង គ្រូពេទ្យ** នឹងត្រូវបានដំឡើងពីចំនួន ១ ២៧២ ៥០០ រៀល នៅឆ្នាំ ២០២២ ដល់ប្រមាណ **១ ៤០០ ០០០** រៀល ចាប់ពីខែមករា ឆ្នាំ ២០២៣;

- **បៀវត្សនគរបាល (ពលបាលត្រី)** នឹងត្រូវបានដំឡើងពីចំនួន ១ ២៥៦ ៩៧៧ រៀល (ដោយគិតបញ្ចូលទាំងរបបអង្គរ) នៅឆ្នាំ ២០២២ ដល់ប្រមាណ **១ ៣៨៤ ៤៧៧ រៀល** (ដោយគិតបញ្ចូលទាំងរបបអង្គរ) ចាប់ពីខែមករា ឆ្នាំ ២០២៣;
- **បៀវត្សយោធិន (ពលទោ)** នឹងត្រូវបានដំឡើងពីចំនួន ១ ១២៣ ៥០០ រៀល (ដោយមិនគិតបញ្ចូលរបបអង្គរ) នៅឆ្នាំ ២០២២ ដល់ប្រមាណ ១ ២៥១ ០០០ រៀល (ដោយមិនគិតបញ្ចូលរបបអង្គរ) ហើយបើគិតបញ្ចូលទាំងរបបអង្គរ ត្រូវជាប្រមាណ **១ ៣០៩ ៤៧៧ រៀល** ចាប់ពីខែមករា ឆ្នាំ ២០២៣។

ទន្ទឹមនេះ, ថវិកាចំនួន **៥០ ប៊ីលានរៀល** ត្រូវបានគ្រោងសម្រាប់មូលនិធិថែទាំសុខភាពជូនមន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងនិវត្តជន និងបានបន្តគ្រោងថវិកាចំនួន **៦ ប៊ីលានរៀល** ដើម្បីទ្រទ្រង់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ នៅក្នុងកញ្ចប់ថវិការបស់ក្រសួងសុខាភិបាល។

ចំពោះ**ប្រាក់សោធននិវត្តន៍** ក៏ត្រូវបានគ្រោងថវិកាចំនួន **១៨១ ប៊ីលានរៀល** សម្រាប់ការដំឡើងប្រាក់សោធនអប្បបរមាប្រចាំខែជូនដល់និវត្តជនដែលជាអតីតមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធផងដែរ ក្នុងគោលដៅជួយគាំទ្រដល់ជីវភាពរបស់ពួកគាត់ ក៏ដូចជាសំដៅកាត់បន្ថយគម្លាតប្រាក់សោធនរបស់និវត្តជន រវាងនិវត្តជនថ្មី និងនិវត្តជនចាស់។ ដូចនេះ **ប្រាក់សោធនអប្បបរមាប្រចាំខែ**របស់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន (អតីតយោធិន និងអតីតមន្ត្រីនគរបាលជាតិ) នឹងត្រូវបានដំឡើងពី ៦៩ ម៉ឺនរៀល ទៅដល់ **៧៧ ម៉ឺនរៀល** ចាប់ពីខែមករា ឆ្នាំ ២០២៣។

**ខ. ចំណាយមិនមែនបន្ទុកបុគ្គលិក** ត្រូវបានគ្រោងចំនួន ១១ ២៨៤ ២២៩ លានរៀល, មានសមាមាត្រស្មើនឹង ៥៤,១% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ, ត្រូវជា ៨,៦០% នៃ ផសស, មានកំណើន ៧,៩% ធៀបនឹងច្បាប់ឆ្នាំ ២០២២។ ជារួម, គ្រប់ក្រសួង-ស្ថាប័នទាំងអស់ ជាទូទៅគោរពបាននូវពិតានចំណាយគោលដែលរាជរដ្ឋាភិបាលបានកំណត់ផ្តល់ជូនសម្រាប់ចំណាយមិនមែនបន្ទុកបុគ្គលិក ហើយកំណើនចំណាយមិនមែនបន្ទុកបុគ្គលិកដែលត្រូវបានគ្រោង គឺសម្រាប់ការបន្តអនុវត្តអាទិភាពចម្បងសំខាន់ៗ រួមមាន៖ ការបន្តគ្រប់គ្រងឱ្យបាននូវការរីករាលដាលនៃជំងឺកូវីដ-១៩; ការបន្តកសាងប្រព័ន្ធគាំពារសង្គមរឹងមាំ និងប្រព័ន្ធសុខាភិបាលប្រកបដោយគុណភាព និងមានភាពឆ្លើយតបខ្ពស់; ការទ្រទ្រង់និរន្តរភាពនៃប្រតិបត្តិការរបស់រដ្ឋ; ការបន្តស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឱ្យស្ទុះងើបឡើងវិញ; ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៧ និងការធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍ និងអាស៊ានប៉ារ៉ាហ្គេម ឆ្នាំ ២០២៣; ព្រមទាំងអាទិភាពមួយចំនួនផ្សេងទៀត។

កញ្ចប់ថវិកានេះ ត្រូវបានវិភាជដោយផ្អែកលើតម្រូវការ និងអាទិភាពចាំបាច់តាមវិស័យនីមួយៗ ដូចខាងក្រោម៖

**<u>ចំណាយវិស័យរដ្ឋបាលទូទៅ៖</u>**

- គាំទ្រដល់**ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៧**;
- គាំទ្រដល់**ការធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ និង អាស៊ានប៉ារ៉ាហ្គេម លើក ទី ១២ ឆ្នាំ ២០២៣**;
- បន្តគាំទ្រដល់សកម្មភាពបោសសម្អាតមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ឆ្ពោះទៅរកកម្ពុជា គ្មានគ្រាប់មីននៅឆ្នាំ ២០២៥ ក្រោមទិសស្លោក **ផ្តល់ដីសុវត្ថិភាព បង្កើតស្នាមញញឹម**;
- បន្តគាំទ្រដល់ការលើកកម្ពស់ប្រសិទ្ធភាពការងារគ្រប់គ្រងចំណូល និងប្រមូលចំណូលសារពើពន្ធ;
- រៀបចំ និងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនមែនធនាគារ;

- បន្តគាំទ្រដល់ធុរកិច្ចថ្មី សហគ្រិនភាព ថ្នាលឌីជីថល និងសេដ្ឋកិច្ចនវានុវត្តន៍;
- បន្តគាំទ្រដល់ការអនុវត្តការងារនិងតួនាទីរបស់ស្ថាប័ននីតិប្បញ្ញត្តិ;
- បន្តគាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ;
- គាំទ្រដល់ការពង្រឹងការគ្រប់គ្រងវិស័យសំណង់ ការរៀបចំប្លង់គោល និងនគរូបនីយកម្ម;
- បន្តគាំទ្រកំណែទម្រង់វិស័យដីធ្លី;
- បន្តគាំទ្រ និងពង្រឹងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មឆ្នាំ ២០១៥-២០២៥;
- បន្តគាំទ្រដល់ការប្រយុទ្ធប្រឆាំងអំពើពុករលួយ;
- បន្តគាំទ្រដល់ការលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចការទូត;
- បន្តគាំទ្រដល់ការចូលរួមក្នុងបេសកកម្មថែរក្សាសន្តិភាពក្នុងក្របខ័ណ្ឌអង្គការសហប្រជាជាតិ ។

**<u>ចំណាយវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ៖</u>**

- បន្តគាំទ្រដល់ការពង្រឹងសមត្ថភាពរបស់នគរបាល និងកងកម្លាំងប្រដាប់អាវុធ;
- បន្តផ្តោតការយកចិត្តទុកដាក់លើជីវភាព និងសុខុមាលភាពកងកម្លាំងប្រដាប់អាវុធ;
- បន្តគាំទ្រដល់កិច្ចដំណើរការរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ និងរដ្ឋបាលតុលាការ;
- បន្តគាំទ្រកិច្ចដំណើរការរដ្ឋបាល និងអន្តរាគមន៍ផ្សេងៗ;
- បន្តគាំទ្រដល់ដំណើរការនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ;
- បន្តគាំទ្រការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព;
- បន្តគាំទ្រដល់ប្រព័ន្ធត្រួតពិនិត្យសន្តិសុខតាមច្រកព្រំដែន និងការផលិតលិខិតឆ្លងដែន;
- បន្តគាំទ្រដល់ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ស្ត្រី និងកុមារ;
- បន្តគាំទ្រដល់កិច្ចការសន្តិសុខជាតិ សកម្មភាពការងារកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ និងការ-ប្រយុទ្ធប្រឆាំងគ្រឿងញៀន;
- បន្តគាំទ្រសេវាឥតគិតថ្លៃរបស់គណៈមេធាវីកម្ពុជា។

**<u>ចំណាយវិស័យសង្គមកិច្ច៖</u>**

- បន្តគ្រប់គ្រងឱ្យបាននូវការរីករាលដាលនៃជំងឺកូវីដ-១៩;
- បន្តគាំទ្រដល់ការលើកកម្ពស់គុណភាព និងការទទួលបានសេវាសុខាភិបាល;
- បន្តគាំទ្រដល់ការពង្រឹងនិងពង្រីកការទទួលបានសេវាអប់រំ និងការលើកកម្ពស់គុណភាពអប់រំ;
- បន្តគាំទ្រដល់ការលើកកម្ពស់វិស័យកីឡាជាតិ;
- បន្តគាំទ្រដល់ការអភិវឌ្ឍជំនាញ និងវិស័យការងារ;
- បន្តផ្តល់របបសន្តិសុខសង្គមរបស់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន;
- បន្តអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ;
- បន្តគាំទ្រដល់ការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារ;
- បន្តឧបត្ថម្ភគាំទ្រដល់សមាគមអតីតយុទ្ធជន;
- បន្តឧបត្ថម្ភដល់មជ្ឈមណ្ឌលស្តារនីតិសម្បទាតាមបណ្តារាជធានី-ខេត្ត និង មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម កាយសម្បទា;
- បន្តផ្តល់ថវិកាគាំទ្រដល់ការដោះស្រាយជីវភាពចំពោះជនក្រីក្រ និងចាស់ជរានៅតាមសហគមន៍;
- បន្តគាំទ្រដល់ការប្រយុទ្ធប្រឆាំងព័ត៌មានក្លែងក្លាយ;

- បន្តគាំទ្រដល់ការការពារ និងអភិរក្សធនធានធម្មជាតិ;
- បន្តគាំទ្រដល់ការអភិរក្ស និងអភិវឌ្ឍន៍វប្បធម៌ជាតិ;
- បន្តគាំទ្រដល់សុខដុមនីយកម្មសាសនា។

**<u>ចំណាយវិស័យសេដ្ឋកិច្ច៖</u>**

- បន្តគាំទ្រដល់ការលើកកម្ពស់បច្ចេកទេសកសិកម្ម និង សុវត្ថិភាពចំណីអាហារ;
- បន្តគាំទ្រដល់ការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច, ការបង្ការទប់ស្កាត់, និងបង្ក្រាបបទល្មើសព្រៃឈើ និងជលផល;
- បន្តគាំទ្រដល់ការពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងធនធានរ៉ែគ្រប់ប្រភេទ;
- បន្តគាំទ្រដល់ការអភិវឌ្ឍទឹកស្អាត និងអនាម័យជនបទ;
- បន្តគាំទ្រដល់ការជួសជុល និងថែទាំប្រព័ន្ធធារាសាស្ត្រ;
- ជំរុញការអភិវឌ្ឍផលិតផល និងការពង្រឹងគុណភាពសេវាទេសចរណ៍;
- ការស្តារព្រៃឈើឡើងវិញ និងសង្គ្រោះសត្វព្រៃ;
- បន្តបើកទីផ្សារសម្រាប់ការនាំចេញរបស់កម្ពុជា;
- បន្តគាំទ្រដល់ការជួសជុល ថែទាំផ្លូវ ស្ពាន និងផ្លូវលំជនបទ ព្រមទាំងការស្តារស្រះ ជីកស្រះ និងអណ្តូងទឹក ដើម្បីទប់ទល់នឹងគ្រោះរាំងស្ងួត;
- បន្តគាំទ្រដល់ការត្រួតពិនិត្យសុវត្ថិភាពចំណីអាហារ;
- បន្តគាំទ្រដល់ការអភិវឌ្ឍវិស័យទូរគមនាគមន៍;
- បន្តគាំទ្រដល់ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម។

លើសពីនេះ សម្រាប់ឆ្នាំ ២០២៣ រាជរដ្ឋាភិបាលក៏បានគ្រោងថវិកាឆ្លើយតបនឹងសកម្មភាពគាំពារសង្គម ដែលរួមមានជាអាទិ៍ដូចជា៖

- **ការបន្តគាំទ្រការថែទាំសុខភាពសម្រាប់កម្មករ៖** បានត្រៀមថវិកាក្នុងកញ្ចប់ថវិការបស់ក្រសួងសុខាភិបាល សម្រាប់ពង្រីកវិសាលភាពមូលនិធិសមធម៌ ដើម្បីផ្តល់លទ្ធភាពឱ្យកម្មករ (ទាំងក្នុងប្រព័ន្ធ និង ក្រៅប្រព័ន្ធ) ដែលមិនទាន់ជាសមាជិកបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) ទទួលបានរបបថែទាំសុខភាពដូចប្រជាជនដែលមានប័ណ្ណក្រីក្រដែរ;
- **ការបន្តការឧបត្ថម្ភមាតុភាពសម្រាប់កម្មករនិយោជិត៖** បានគ្រោងនៅក្នុងកញ្ចប់ថវិការបស់ក្រសួងសុខាភិបាលសម្រាប់បន្តបើកផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មការិនី នៅក្រោយពេលសម្រាលកូន និងសម្រាកលំហែមាតុភាព;
- **ការបន្តនិរន្តរភាពមន្ទីរពេទ្យគន្ធបុប្ផា៖** បន្តផ្តល់ថវិកាសម្រាប់បង្កើន "**មូលនិធិគន្ធបុប្ផាកម្ពុជា**" បន្ថែមលើថវិកាដែលត្រូវផ្តល់ផ្ទាល់ទៅមន្ទីរពេទ្យគន្ធបុប្ផាសម្រាប់ចំណាយប្រតិបត្តិការឆ្នាំ ២០២២, ដើម្បីធានានិរន្តរភាព គុណភាព និងប្រសិទ្ធភាព របស់មន្ទីរពេទ្យផង និងធានាការផ្តល់សេវាដោយមិនយកថ្លៃជូនដល់កុមារនៃគ្រួសារក្រីក្រផង;
- **កម្មវិធីផ្ទេរសាច់ប្រាក់សម្រាប់ស្ត្រីក្រីក្រមានផ្ទៃពោះ និងកុមារតូច៖** បានគ្រោងថវិកាសម្រាប់ឧបត្ថម្ភ ពេលពិនិត្យផ្ទៃពោះ ចំនួន ៤ លើក, ១ លើក ៤ ម៉ឺនរៀល; ពេលសម្រាលកូននៅមណ្ឌលសុខភាព ឬពេទ្យរដ្ឋ ជូន ២០ ម៉ឺនរៀល; ឧបត្ថម្ភ ១០ លើកទៀត; ១ លើក ៤ ម៉ឺនរៀល ពេលទៅទទួលថ្នាំបង្ការរហូតដល់កុមារអាយុ ២ ឆ្នាំ។

គ. **<u>ចំណាយមូលធនថ្នាក់ជាតិ</u>** ត្រូវបានគ្រោងចំនួន ១៥ ៧៦៤ ២៧៣ លានរៀល, មានសមាមាត្រស្មើនឹង ៤៣,១% នៃចំណាយថវិកាថ្នាក់ជាតិសរុប, ត្រូវជា ១២,០១% នៃ ផសស, មានកំណើន ១៧,១% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២២, **ក្នុងគោលដៅគាំទ្រដល់ការបន្តអនុវត្តកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល** (២០២៣-២០២៥) ជាពិសេសការអនុវត្ត **"យុទ្ធសាស្ត្រស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី"។ គម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេសនៅថ្នាក់ជាតិ** ត្រូវបានគ្រោងចំនួន ៧ ៧៣០ ៩៧១ លានរៀល, ត្រូវជា ៥,៨៩% នៃ ផសស, កើនឡើង ២៥,២% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២២ ដោយផ្តោតអាទិភាពទៅលើ៖

- ការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ ស្ពាន លូ ព្រមទាំងការជួសជុលឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធដែលរងផលប៉ះពាល់ពីជំនន់ទឹកភ្លៀង រួមទាំងការកសាងហេដ្ឋារចនាសម្ព័ន្ធ ដូចជា ប្រព័ន្ធចម្រោះទឹកកខ្វក់ ប្រព័ន្ធលូ អូរ ប្រឡាយរំដោះទឹកភ្លៀង និងប្រព័ន្ធបង្ហូរទឹកកខ្វក់;
- ការបន្តស្តារ និងកសាងប្រព័ន្ធធារាសាស្ត្រ និងលើកកម្ពស់ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងធារាសាស្ត្រ;
- ការជំរុញផលិតកម្មស្បៀង និងការលើកកម្ពស់ផលិតភាពកសិកម្ម;
- ការបន្តកសាងហេដ្ឋារចនាសម្ព័ន្ធវិស័យអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធចាំបាច់មួយចំនួនផ្សេងទៀត ។

ក្រៅពីចំណាយគាំទ្រវិស័យសំខាន់ៗទាំង ៤ ខាងលើ, រាជរដ្ឋាភិបាលក៏បានគ្រោងថវិកាសម្រាប់ការបន្តអន្តរាគមន៍ទប់ទល់នឹងផលប៉ះពាល់ពីជំងឺកូវីដ-១៩ និងសម្ពាធអតិផរណា មានជាអាទិ៍ ដូចខាងក្រោម៖

- កម្មវិធីឧបត្ថម្ភសាច់ប្រាក់ដល់គ្រួសារក្រីក្រ (ក្រ១, ក្រ២) និងជនងាយរងគ្រោះ និងកញ្ចប់ឧបត្ថម្ភគ្រួសារ ត្រូវបានគ្រោងថវិកាចំនួន ១ ៦២៦ ប៊ីលានរៀល, សមមូលនឹងប្រមាណ ៤០០ លានដុល្លារអាម៉េរិក, សម្រាប់រយៈពេល ១២ ខែ;
- កម្មវិធីឧបត្ថម្ភសាច់ប្រាក់មួយគ្រាជូនគ្រួសារដែលងាយរងហានិភ័យ (គ្រួសារដែលមានជីវភាពកៀកនឹងបន្ទាត់នៃភាពក្រីក្រ) ចំនួន ២៦៤,២ ប៊ីលានរៀល, សមមូលនឹងប្រមាណ ៦៥ លានដុល្លារអាម៉េរិក;
- កម្មវិធីបណ្តុះបណ្តាលសមត្ថភាពជំនាញវិជ្ជាជីវៈ និងការជួយកម្មករព្យួរកិច្ចសន្យាការងារ ត្រូវបានគ្រោងថវិកាចំនួន ២៤៣,៩ ប៊ីលានរៀល, សមមូលនឹងប្រមាណ ៦០ លានដុល្លារអាម៉េរិក;
- គម្រោងសាច់ប្រាក់ពលកម្ម (Cash for Works) ត្រូវបានគ្រោងថវិកាចំនួន ៤០៦,៥ ប៊ីលានរៀល, សមមូលនឹងប្រមាណ ១០០ លានដុល្លារអាម៉េរិក, សម្រាប់បង្កើតការងារ និងកសាងហេដ្ឋារចនា-សម្ព័ន្ធរូបវន្តនៅជនបទ រួមមាន ប្រឡាយជើងក្អែម ស្រះទឹក អណ្តូង និងបង្គន់អនាម័យនៅតាមសាលារៀនជាដើម;
- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនានា នៅតំបន់អភិវឌ្ឍន៍រុនតាឯក និងតំបន់អភិវឌ្ឍន៍ពាក់ស្នែង ខេត្តសៀមរាប ចំនួន ១០០ ប៊ីលានរៀល, សមមូលស្មើនឹងប្រមាណ ២៥ លានដុល្លារអាម៉េរិក;
- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងបៃតង ត្រូវបានគ្រោងថវិកាចំនួន ២០៣,៣ ប៊ីលានរៀល, សមមូលនឹងប្រមាណ ៥០ លានដុល្លារអាម៉េរិក;
- ការអនុវត្តយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនចំនួន ៤០៦,៥ ប៊ីលានរៀល, សមមូលនឹងប្រមាណ១០០ លានដុល្លារអាម៉េរិក;
- ឧបករណ៍ផ្តល់ហិរញ្ញប្បទានបន្ថែមដល់សហគ្រាសធុនតូច និងមធ្យមចំនួន ៤០៦,៥ ប៊ីលានរៀល, សមមូលនឹងប្រមាណ ១០០ លានដុល្លារអាម៉េរិក;
- ការជំរុញពិពិធកម្មសេដ្ឋកិច្ច និងភាពប្រកួតប្រជែងចំនួន ១២២ ប៊ីលានរៀល, សមមូលនឹងប្រមាណ ៣០ លានដុល្លារអាម៉េរិក។

## ជាលទ្ធផលរួម ថវិកាថ្នាក់ជាតិត្រូវបានបែងចែកទៅតាមវិស័យទាំង ៤ ដូចខាងក្រោម៖

| ចំណាយថវិកាតាមវិស័យ (ឯកតាលានរៀល) | ២០២២ | | ២០២៣ | | % កំណើន |
|---|---|---|---|---|---|
| | ច្បាប់ | % ផសស | គ្រោង | % ផសស | |
| **១. វិស័យរដ្ឋបាលទូទៅ** | **2,088,946** | **1.74%** | **3,079,429** | **2.35%** | **47.4%** |
| **ក. ចំណាយចរន្ត** | **1,916,131** | **1.59%** | **2,841,034** | **2.16%** | **48.3%** |
| -បន្ទុកបុគ្គលិក | 694,130 | 0.58% | 762,262 | 0.58% | 9.8% |
| -ក្រៅបន្ទុកបុគ្គលិក | 1,222,001 | 1.02% | 2,078,772 | 1.58% | 70.1% |
| **ខ. ចំណាយមូលធន** | **172,815** | **0.14%** | **238,395** | **0.18%** | **37.9%** |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 0 | | 0 | | |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 172,815 | 0.14% | 238,395 | 0.18% | 37.9% |
| **២. វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ** | **4,795,111** | **3.99%** | **5,215,546** | **3.97%** | **8.8%** |
| **ក. ចំណាយចរន្ត** | **4,675,287** | **3.89%** | **5,101,874** | **3.89%** | **9.1%** |
| -បន្ទុកបុគ្គលិក | 3,822,770 | 3.18% | 4,184,410 | 3.19% | 9.5% |
| -ក្រៅបន្ទុកបុគ្គលិក | 852,517 | 0.71% | 917,464 | 0.70% | 7.6% |
| **ខ. ចំណាយមូលធន** | **119,824** | **0.10%** | **113,672** | **0.09%** | **-5.1%** |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 22,600 | 0.02% | 30,000 | 0.02% | 32.7% |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 97,224 | 0.08% | 83,672 | 0.06% | -13.9% |
| **៣. វិស័យសង្គមកិច្ច** | **8,449,790** | **7.02%** | **8,989,718** | **6.85%** | **6.4%** |
| **ក. ចំណាយចរន្ត** | **7,332,061** | **6.09%** | **7,927,353** | **6.04%** | **8.1%** |
| -បន្ទុកបុគ្គលិក | 3,610,626 | 3.00% | 4,027,946 | 3.07% | 11.6% |
| -ក្រៅបន្ទុកបុគ្គលិក | 3,721,435 | 3.09% | 3,899,408 | 2.97% | 4.8% |
| **ខ. ចំណាយមូលធន** | **1,117,729** | **0.93%** | **1,062,365** | **0.81%** | **-5.0%** |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 110,000 | 0.09% | 130,000 | 0.10% | 18.2% |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 1,007,729 | 0.84% | 932,365 | 0.71% | -7.5% |
| **៤. វិស័យសេដ្ឋកិច្ច** | **6,531,922** | **5.43%** | **7,046,053** | **5.37%** | **7.9%** |
| **ក. ចំណាយចរន្ត** | **1,457,206** | **1.21%** | **1,582,070** | **1.21%** | **8.6%** |
| -បន្ទុកបុគ្គលិក | 526,429 | 0.44% | 580,579 | 0.44% | 10.3% |
| -ក្រៅបន្ទុកបុគ្គលិក | 930,777 | 0.77% | 1,001,491 | 0.76% | 7.6% |
| **ខ. ចំណាយមូលធន** | **5,074,716** | **4.22%** | **5,463,983** | **4.16%** | **7.7%** |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 539,000 | 0.45% | 545,000 | 0.42% | 1.1% |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 4,535,716 | 3.77% | 4,918,983 | 3.75% | 8.4% |

## ទំហំចំណាយថវិកាសរុបរបស់ក្រសួង-ស្ថាប័ន សម្រាប់ឆ្នាំ ២០២៣




## ចំណាយថវិកាសរុបរបស់ក្រសួង-ស្ថាប័ន សម្រាប់ឆ្នាំ ២០១៣-២០២៣ (ចំណាយចរន្ត និង ចំណាយមូលធន)



### ៤.២.២-ថវិកាថ្នាក់ក្រោមជាតិ

| ថវិកាថ្នាក់ក្រោមជាតិ (ឯកតាលានរៀល) | ២០២២ | | ២០២៣ | | % កំណើន |
|---|---|---|---|---|---|
| | ច្បាប់ | % ផសស | គ្រោង | % ផសស | |
| ចំណូលចរន្តថវិកាថ្នាក់ក្រោមជាតិ | 2,131,764 | 1.77% | 2,602,507 | 1.98% | 22.1% |
| • *ចំណូលសារពើពន្ធ* | 1,584,127 | 1.32% | 2,172,350 | 1.65% | 37.1% |
| • *ចំណូលមិនមែនសារពើពន្ធ* | 547,637 | 0.46% | 430,157 | 0.33% | -21.5% |
| សរុបចំណាយថវិកាថ្នាក់ក្រោមជាតិ | 3,394,814 | 2.82% | 4,061,797 | 3.09% | 19.6% |
| • *ចំណាយចរន្ត* | 3,001,786 | 2.49% | 3,548,797 | 2.70% | 18.2% |
| • *ចំណាយមូលធន* | 393,028 | 0.33% | 513,000 | 0.39% | 30.5% |
| ឱនភាពថវិកា | -1,263,050 | -1.05% | -1,459,290 | -1.11% | 15.5% |
| ឧបត្ថម្ភដល់ថ្នាក់ក្រោមជាតិ | 1,263,050 | 1.05% | 1,459,290 | 1.11% | 15.5% |
| • *រាជធានី-ខេត្ត (សម្រាប់រដ្ឋបាលខណ្ឌ)* | 13,304 | 0.01% | 14,226 | 0.01% | 6.9% |
| • *ក្រុង-ស្រុក* | 402,389 | 0.33% | 470,141 | 0.36% | 16.8% |
| • *ឃុំ-សង្កាត់* | 650,297 | 0.54% | 753,350 | 0.57% | 15.8% |
| • *មូលនិធិអភិវឌ្ឍន៍ឃុំ-សង្កាត់* | 197,060 | 0.16% | 221,573 | 0.17% | 12.4% |

គម្រោងចំណូល-ចំណាយរបស់រដ្ឋបាលរាជធានី-ខេត្ត, ក្រុង-ស្រុក, និងឃុំ-សង្កាត់ ខាងលើ បានធ្វើឱ្យមានឱនភាពថវិកាចំនួន ១ ៤៥៩ ២៩០ លានរៀល, ត្រូវជា ១,១១% នៃ ផសស, ដែលត្រូវបានគ្រោងឧបត្ថម្ភធនបំពេញតុល្យភាពដោយថវិកាថ្នាក់ជាតិ ដែលការឧបត្ថម្ភនេះកើនឡើង ១៥,៥% ធៀបនឹងច្បាប់ឆ្នាំ ២០២២ ក្នុងនោះ៖

(១)- **ឧបត្ថម្ភរាជធានី-ខេត្ត(សម្រាប់រដ្ឋបាលខណ្ឌ)** ចំនួន ១៤ ២២៦ លានរៀល ដើម្បីអនុវត្តការផ្ទេរមុខងាររបស់មន្ទីរជំនាញ;

(២)- **ឧបត្ថម្ភក្រុង-ស្រុក** ចំនួន ៤៧០ ១៤១ លានរៀល, មានកំណើន ១៦,៨% ធៀបនឹងច្បាប់ឆ្នាំ ២០២២;

(៣)- **ឧបត្ថម្ភឃុំ-សង្កាត់** ចំនួន ៧៥៣ ៣៥០ លានរៀល, មានកំណើន ១៥,៨% ធៀបនឹងច្បាប់ឆ្នាំ ២០២២;

(៤)- **ឧបត្ថម្ភមូលនិធិអភិវឌ្ឍន៍ឃុំ-សង្កាត់** ចំនួន ២២១ ៥៧៣ លានរៀល, ស្មើនឹង ០,១៧% នៃ ផសស មានកំណើន ១២,៤% ធៀបនឹងច្បាប់ឆ្នាំ ២០២២, ដែលជាការផ្ទេរធនធានបន្ថែមជូនរដ្ឋបាលឃុំ-សង្កាត់សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន ចាប់ពីឆ្នាំ ២០២០ ដល់ឆ្នាំ ២០២៣។ ការឧបត្ថម្ភធនបន្ថែមនេះ នឹងធ្វើឱ្យរដ្ឋបាលឃុំ-សង្កាត់នីមួយៗ ទទួលបានថវិកាសរុបជាមធ្យមប្រមាណ **៦៣៣ លានរៀល** ឬសមមូលនឹង **១៥៦ ៤២០ ដុល្លារអាម៉េរិក** ក្នុងនោះ ថវិកាសម្រាប់ផ្នែកអភិវឌ្ឍន៍មូលដ្ឋានឃុំ-សង្កាត់នីមួយៗ ទទួលបានជាមធ្យមប្រមាណ **៣៥៨ លានរៀល** ឬសមមូលនឹង **៨៨ ០០០ ដុល្លារអាម៉េរិក** ក្នុង១ឆ្នាំ, កើនឡើង ២២,២% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២២។

ជាមួយនឹងការបង្កើនចំណាយដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍន៍នៅរដ្ឋបាលថ្នាក់ក្រោមជាតិ, អាទិភាពចំណាយត្រូវបានផ្ដល់ដល់ការដំឡើងប្រាក់បំណាច់ជូនដល់ ក្រុមប្រឹក្សារាជធានី-ខេត្ត, ក្រុង-ស្រុក-ខណ្ឌ, ឃុំ-សង្កាត់ និងមន្ត្រីភូមិផងដែរ។ ដូចនេះ ប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់មន្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិគិតចាប់ពីខែមករា ឆ្នាំ ២០២៣ នឹងមានកំណើន ដូចខាងក្រោម៖

- **ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត** នឹងទទួលបានប្រាក់ឧបត្ថម្ភកើនឡើងដល់ **១ ៥៧០ ០០០ រៀល**;

- **សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត** នឹងទទួលបានប្រាក់ឧបត្ថម្ភកើនឡើងដល់ **១ ១៩៥ ០០០ រៀល;**
- **ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ** នឹងទទួលបានប្រាក់ឧបត្ថម្ភកើនឡើងដល់ **១ ២៨៥ ០០០ រៀល;**
- **សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ** នឹងទទួលបានប្រាក់ឧបត្ថម្ភកើនឡើងដល់ **៩៧០ ០០០ រៀល;**
- **ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់** នឹងទទួលបានប្រាក់ឧបត្ថម្ភកើនឡើងដល់ **១ ២៤០ ០០០ រៀល;**
- **ជំទប់ទី១ , ចៅសង្កាត់រងទី១** នឹងទទួលបានប្រាក់ឧបត្ថម្ភកើនឡើងដល់ **៩៣០ ០០០ រៀល;**
- **ជំទប់ទី២ , ចៅសង្កាត់រងទី២** នឹងទទួលបានប្រាក់ឧបត្ថម្ភកើនឡើងដល់ **៩៣០ ០០០ រៀល;**
- **សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់** នឹងទទួលបានប្រាក់ឧបត្ថម្ភកើនឡើងដល់ **៨២០ ០០០ រៀល;**
- **មេភូមិ** នឹងទទួលបានប្រាក់ឧបត្ថម្ភកើនឡើងដល់ **៥១០ ០០០ រៀល;**
- **អនុប្រធានភូមិ** នឹងទទួលបានប្រាក់ឧបត្ថម្ភកើនឡើងដល់ **៣៩០ ០០០ រៀល;**
- **សមាជិកភូមិ** នឹងទទួលបានប្រាក់ឧបត្ថម្ភកើនឡើងដល់ **៣៦០ ០០០ រៀល ។**

### ៤.២.៣-អំពីការខ្ចី

ក្នុងការគ្រប់គ្រងបំណុលសាធារណៈ, រាជរដ្ឋាភិបាលប្រកាន់ខ្ជាប់នូវគោលការណ៍គន្លឹះចំនួន ៥ ដូចខាងក្រោម៖

(១)- ខ្ចីឥណទានក្នុងទំហំសមស្របដែលស្ថានភាពថវិកា និងសេដ្ឋកិច្ចអាចទ្រាំទ្របាន;

(២)- ខ្ចីតែឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់;

(៣)- ខ្ចីសម្រាប់តែវិស័យអាទិភាពទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ច និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ច ឬផលិតភាពផលិតកម្ម;

(៤)- ប្រើប្រាស់ឥណទាន ប្រកបដោយតម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព, និងស័ក្តិសិទ្ធភាពខ្ពស់បំផុត;

(៥)- ប្រើប្រាស់ឥណទានសម្រាប់ហិរញ្ញប្បទានគម្រោងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដែលត្រូវមានស្តង់ដា និងគុណភាពខ្ពស់ ស្របតាមគោលការណ៍នៃការគ្រប់គ្រងការវិនិយោគសាធារណៈ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍន៍ជាតិនៅក្នុងដំណាក់កាលថ្មី ពិសេស ធានាបាននូវចីរភាពសេដ្ឋកិច្ច, សង្គម, បរិស្ថាន, និងភាពធន់នឹងបម្រែបម្រួលអាកាសធាតុ។

នៅឆ្នាំ ២០២៣ រាជរដ្ឋាភិបាល គ្រោងនឹងបោះផ្សាយលក់មូលបត្ររដ្ឋជាលើកទីពីរ ចំនួន ២០០ លានដុល្លារអាមេរិក សម្រាប់សងប្រាក់ដើមនៃការបោះផ្សាយមូលប័ត្រឆ្នាំ ២០២២ ចំនួន ២០០ ០០០ លានរៀល, សមមូលនឹងប្រមាណ ៤៩ លានដុល្លារអាមេរិក និង ការគ្រោងថវិកាចំនួន ៦១៣ ៨១៥ លានរៀល, សមមូលនឹងប្រមាណ ១៥១ លានដុល្លារអាមេរិកទៀត សម្រាប់ធ្វើហិរញ្ញប្បទានលើគម្រោងវិនិយោគដែលអាចផ្តល់ចំណូលដោយត្រង់មករាជរដ្ឋាភិបាល និងផ្តល់ផលរហ័ស ដើម្បីធានាប្រសិទ្ធភាពនៃការវិនិយោគ និងចិរភាពនៃការគ្រប់គ្រងបំណុល និងថវិកាជាតិ ។

ទន្ទឹមនេះ, រាជរដ្ឋាភិបាលកំណត់ទំហំនៃការខ្ចីប្រាក់ពីដៃគូអភិវឌ្ឍសម្រាប់ឆ្នាំ ២០២៣ ក្នុងកម្រិត ១ ៧០០ លានSDR គឺកើនឡើង១០០លានSDR ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២២ ដោយផ្អែកលើទិដ្ឋភាព៖ (១)-ទំហំនៃតម្រូវការវិនិយោគសាធារណៈមានការកើនឡើង ដែលកម្ពុជាមានភាពចាំបាច់ក្នុងការកៀរគរធនធានបន្ថែមឱ្យបានច្រើនដើម្បីបំពេញតម្រូវការសម្រាប់ជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ; (២)-គម្រោងអភិវឌ្ឍន៍ដែលនឹងចុះកិច្ចព្រមព្រៀងឥណទានសម្បទានក្នុងឆ្នាំ ២០២៣ ជាគម្រោងវិនិយោគសាធារណៈក្នុងវិស័យអាទិភាព (ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការបង្កើនផលិតភាពសេដ្ឋកិច្ច និងផលិតភាពផលិតកម្ម) ហើយដែលត្រូវបានកំណត់

ពីឆ្នាំមុនៗមក តែមានចរិតយុទ្ធសាស្ត្រក្នុងការទ្រទ្រង់ដល់ចីរភាពនៃកំណើនសេដ្ឋកិច្ច ក្នុងរយៈពេលមធ្យម និងវែង; (៣)-ឥណទានមានកម្រិតសម្បទានខ្ពស់; (៤)-ស្ថានភាពបំណុលសាធារណៈកម្ពុជាបច្ចុប្បន្ន និងក្នុងរយៈពេលមធ្យម នៅតែមាន **"ចីរភាព" និង "ហានិភ័យកម្រិតទាប"**; និង (៥)-ការបន្តបង្កើនប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រង និងអនុវត្តគម្រោង។ គម្រោងសំខាន់ៗ ត្រូវបានបែងចែកតាមវិស័យ ដូចខាងក្រោម៖

- **វិស័យថាមពលចំនួន ៧ គម្រោងគឺ៖** គម្រោងពង្រីកសមត្ថភាពផ្គត់ផ្គង់អគ្គិសនី ជំហានទី១, គម្រោងពង្រីកសមត្ថភាពផ្គត់ផ្គង់អគ្គិសនី ជំហានទី២, គម្រោងពង្រីកខ្សែបញ្ជូនអគ្គិសនីជនបទ ជំហានទី៨, គម្រោងពង្រីកប្រព័ន្ធខ្សែបញ្ជូន និងចែកចាយនៅរាជធានីភ្នំពេញជំហានទី២ (កញ្ចប់ឥណទានទី៣), គម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនី ១១៥ គីឡូវ៉ុល និងពង្រីកបណ្តាញអគ្គិសនីជនបទ, គម្រោងប្រសិទ្ធភាពថាមពលសម្រាប់ការផ្គត់ផ្គង់អគ្គិសនីជនបទ ជំហានទី២, គម្រោងពង្រឹងសមត្ថភាពប្រព័ន្ធខ្សែបញ្ជូនអគ្គិសនី (ហិរញ្ញប្បទានបន្ថែម);
- **វិស័យធារាសាស្ត្រចំនួន ៥ គម្រោងគឺ៖** គម្រោងអភិវឌ្ឍន៍អាងទឹកដងកាំបិត ខេត្តកំពង់ធំ, គម្រោងកាត់បន្ថយគ្រោះទឹកជំនន់និងអភិវឌ្ឍន៍ធារាសាស្ត្របរវេល ខេត្តបាត់ដំបង, កម្មវិធីគ្រប់គ្រងធនធានទឹក និងការផ្លាស់ប្តូរវិស័យកសិកម្មសម្រាប់ប្រទេសកម្ពុជា ជំហានទី២, គម្រោងគ្រប់គ្រងធនធានទឹកចម្រុះ, គម្រោងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ និងកសិកម្ម ដែលធន់នឹងការប្រែប្រួលអាកាសធាតុ;
- **វិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តចំនួន ៦ គម្រោងគឺ៖** គម្រោងសាងសង់ស្ពានទន្លេបាសាក់(ចាក់អង្រែក្រោម-ព្រែកប្រា), គម្រោងលើកកម្រិតកំណាត់ផ្លូវជាតិលេខ៣(គ.ម.លេខ១៨១+១០០-វាលរេញ), គម្រោងរៀបចំច្រកទ្វារអន្តរជាតិស្ទឹងបត់និងផ្លូវតភ្ជាប់ផ្លូវជាតិលេខ៥(ជំហានទី២), គម្រោងធ្វើឱ្យប្រសើរឡើងនូវកំណាត់ផ្លូវជាតិលេខ៥ ពីថ្លាម្អម ខេត្តពោធិ៍សាត់-ក្រុងបាត់ដំបង និងពីក្រុងសិរីសោភ័ណ-ក្រុងប៉ោយប៉ែត(កញ្ចប់ឥណទានទី៣), គម្រោងកែលម្អការតភ្ជាប់ជនបទ, គម្រោងកែលម្អការតភ្ជាប់ជនបទភូមិភាគឦសាន;
- **វិស័យសុខាភិបាលចំនួន ១ គម្រោងគឺ៖** គម្រោងធ្វើឱ្យប្រសើរឡើងមន្ទីរពេទ្យបង្អែកខេត្ត;
- **វិស័យអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន ១ គម្រោងគឺ៖** គម្រោងបណ្តុះបណ្តាលជំនាញសម្រាប់តម្រូវការសេដ្ឋកិច្ចពេលអនាគត;
- **វិស័យកសិកម្មចំនួន ៣ គម្រោងគឺ៖** គម្រោងជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ, កម្មវិធីអភិវឌ្ឍន៍កសិកម្មតំបន់ពឹងលើទឹកភ្លៀងសម្រាប់ប្រទេសកម្ពុជា, កម្មវិធីគាំទ្រសេដ្ឋកិច្ចជនបទ និងពាណិជ្ជកម្មផលិតផលកសិកម្ម;
- **វិស័យអាទិភាពផ្សេងទៀតចំនួន ៥ គម្រោងគឺ៖** កម្មវិធីវិមជ្ឈការសេវាសាធារណៈនិងការគ្រប់គ្រងហិរញ្ញវត្ថុ ជំហានទី២ អនុកម្មវិធីទី១, កម្មវិធីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អនុកម្មវិធីទី២ , គម្រោងសន្តិសុខទឹកចម្រុះ និងគ្រប់គ្រងធនធានធម្មជាតិ, គម្រោងសេដ្ឋកិច្ចឌីជីថល និងការវិនិយោគលើការប្រកួតប្រជែងនៅកម្ពុជា, គម្រោងគ្រប់គ្រងកាកសំណល់រឹង និងផ្លាស្ទិក។

គួរគូសបញ្ជាក់ថា **ការបោះផ្សាយលក់មូលបត្ររដ្ឋជាលើកទី ២** និង**ការខ្ចីក្នុងទំហំខាងលើនេះ** នឹងមិនបង្កើតជាបន្ទុកបំណុលវ័ណ្ឌកដល់កម្ពុជាទេ ពោលគឺជាទិដ្ឋភាពបច្ចេកទេស ស្ថានភាពបំណុលសាធារណៈកម្ពុជានៅតែត្រូវបានវាយតម្លៃថាមាន **«ចីរភាព»** និង **«ហានិភ័យកម្រិតទាប»** ដដែល ដោយរាល់សូចនាករបំណុលគន្លឹះៗ របស់កម្ពុជា សុទ្ធតែស្ថិតក្រោមអនុបាតគោលទាំងអស់។

## សន្និធិបំណុលសាធារណៈក្រៅប្រទេស គិតត្រឹមត្រីមាសទី ៣ ឆ្នាំ ២០២២




## អនុបាតបំណុលគន្លឹះទាំង ៤




### ៥- សេចក្តីសន្និដ្ឋាន

ថវិកាឆ្នាំ ២០២៣ ត្រូវបានគិតគូរ និងរៀបចំឡើងក្នុងបរិការណ៍នៃការបន្តស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឱ្យស្ថិតនៅលើគន្លងនៃកំណើនខ្ពស់ និងរស់រវើកឡើងវិញ តាមគន្លងប្រក្រតីថ្មីក្នុងការរស់នៅជាមួយនឹងជំងឺកូវីដ-១៩ ព្រមទាំងការបន្តរក្សាលំនឹងជីវភាពរស់នៅរបស់ប្រជាជន និងលំនឹងនៃសង្គម-សេដ្ឋកិច្ច ក៏ដូចជាដើម្បីសម្រេចឱ្យបាននូវគោលដៅសំខាន់ៗ នៃ **កម្មវិធីនយោបាយ** របស់រាជរដ្ឋាភិបាល ដែលត្រូវបានកំណត់

នៅក្នុង "**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤**" និង "**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០១៩-២០២៣**" ជាពិសេស វិធានការអន្តរាគមន៍ដែលត្រូវបានដាក់ចេញក្នុង "ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣" ក្នុងខណៈដែលរាជរដ្ឋាភិបាលក៏មានតម្រូវការចាំបាច់ក្នុងការតម្រង់ការប្រើប្រាស់ធនធានឆ្ពោះទៅអនុវត្តអាទិភាពគោលនយោបាយសំខាន់ៗ នៅឆ្នាំ ២០២៣ ដែលជាឆ្នាំចុងក្រោយនៃអាណត្តិរាជរដ្ឋាភិបាលនីតិកាលទី ៦ ដែលមានជាអាទិ៍៖ *ការដំឡើងបៀវត្សជូនមន្ត្រីរាជការ; ការដំឡើងប្រាក់សោធនជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ជាអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ជាពិសេសការកាត់បន្ថយគម្លាតប្រាក់សោធនរវាងអ្នកចូលនិវត្តន៍ចាស់ និងថ្មី; ការបន្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ដល់គ្រួសារក្រីក្រ (ក្រ១ និងក្រ២) និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់មួយគ្រាជូនគ្រួសារងាយរងហានិភ័យ ក្នុងអំឡុងពេលមានសម្ពាធអតិផរណា; ការជំរុញការងើបឡើងវិញនៃសេដ្ឋកិច្ចកម្ពុជា; ការបន្តអនុវត្តកម្មវិធីសាច់ប្រាក់ពលកម្ម; កម្មវិធីអន្តរាគមន៍លើផ្នែកបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ; ព្រមទាំងការអនុវត្តគម្រោងអភិវឌ្ឍន៍តំបន់រុនតាឯក និងតំបន់អភិវឌ្ឍន៍ពាក់ស្នែង; និងការត្រៀមដោះស្រាយថវិកាសម្រាប់អគ្គិសនីកម្ពុជា ដើម្បីធានាស្ថិរភាពថ្លៃអគ្គិសនីកុំឱ្យលើសកម្រិតថ្លៃអនុវត្តបច្ចុប្បន្នជូនប្រជាពលរដ្ឋប្រើប្រាស់;* និងជាពិសេស *គឺការធានាជោគជ័យនៃកិច្ចដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ និងការធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍ និងអាស៊ានប៉ារ៉ាហ្គេមឆ្នាំ ២០២៣* ។

សរុបមក, ថវិកាឆ្នាំ ២០២៣ អាចត្រូវបានសន្និដ្ឋានថា ជាឧបករណ៍ដ៏មានប្រសិទ្ធភាពដែលអាចជួយឱ្យរាជរដ្ឋាភិបាលអាចឆ្លើយតបទៅនឹងបញ្ហាប្រឈម និងហានិភ័យផងទាំងពួង, ទាំងក្នុង និងក្រៅប្រទេស, សំដៅបន្តការពារអាយុជីវិត លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនពលរដ្ឋ ព្រមទាំងស្តារ និងជំរុញការងើបឡើងវិញនូវកំណើនសេដ្ឋកិច្ចកម្ពុជា ទន្ទឹមនឹងការរៀនរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី ហើយអាចប្រសិទ្ធនាមបានថាជា «ថវិកាវិត្តារកម្មចំគោលដៅ ដោយផ្តល់អាទិភាពទី ១ ដល់ "មនុស្ស" ពិសេសផ្តោតលើ សុខភាព ជីវភាព និងសមធម៌ ព្រមជាមួយនឹងអាទិភាពនៃការបន្តជំរុញការងើបឡើងវិញនៃកំណើនសេដ្ឋកិច្ច ស្របតាម "ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣" ក៏ដូចជាកិច្ចប្រឹងប្រែងសម្រេចឱ្យបានជាអតិបរមានូវគោលដៅអភិវឌ្ឍន៍សំខាន់ៗ ស្របតាមរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលត្រូវបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣»។

*ថ្ងៃសុក្រ ៤កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦*

*រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០២២*

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ